# ព្រះរាជក្រម

នស/រកម/១២០៦/០៣៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
  បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់

# ការគ្រប់គ្រងឆ្នាំ ២០០៧

# ជំពូកទី ១
# បទប្បញ្ញត្តិស្តីពីវិសោធនកម្ម

## ផ្នែកទី ១
## បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រាមួយចំនួន នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

**មាត្រា ១.-**

មាត្រា ៦ មាត្រា ៧ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ មាត្រា ១៧ មាត្រា ២៦ មាត្រា ៣៥ មាត្រា ៣៩ មាត្រា ៤២ មាត្រា ៥៤ និងមាត្រា ៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ព្រមទាំងត្រូវបានកែប្រែដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ត្រូវបានកែប្រែដោយបទប្បញ្ញត្តិដូចតទៅ :

**មាត្រា ៦.-ថ្មី**

ធនធានអចិន្ត្រៃយ៍របស់ថវិការដ្ឋមាន ចំណូលជាប្រក្រតី និងចំណូលជាមូលធន ។

ចំណូលជាប្រក្រតី ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

ក្រុមទី ១ : ចំណូលពិត

-ប្រភេទទី ១ : ចំណូលសារពើពន្ធ

-ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ

ក្រុមទី ២ : ចំណូលតាមដីកា

-ប្រភេទទី ៣ : ចំណូលតាមដីកា

ចំណូលជាមូលធន ត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

ក្រុមទី ១ : ចំណូលពិត

-ប្រភេទទី ១ : ចំណូលពីប្រភពផ្ទាល់

-ប្រភេទទី ២ : ចំណូលពីប្រភពខាងក្រៅ

ក្រុមទី ២ : ចំណូលតាមដីកា

-ប្រភេទទី ៣ : ចំណូលតាមដីកា

ប្រភេទចំណូលនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុអាចលំអិតជាងនេះទៀតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៧.–ថ្មី**

ចំណូលសារពើពន្ធរួមមានចំណូលសារពើពន្ធក្នុងប្រទេស និង ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ។

ចំណូលមិនមែនសារពើពន្ធរួមមាន ផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនលើការលក់ ឬជួលទ្រព្យសម្បត្តិ និង សេវា ផលពីការពិន័យ ការឧបត្ថម្ភ-អំណោយ ផលហិរញ្ញវត្ថុ និងផលពិសេស ។

ចំណូលជាមូលធនរួមមានអចលកម្មហិរញ្ញវត្ថុផ្សេងៗ ឧបត្ថម្ភកធនវិនិយោគ និងការខ្ចី ។

**មាត្រា ១៣.–ថ្មី**

បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋរួមមាន ចំណាយជាប្រក្រតី និង ចំណាយជាមូលធន ។ បន្ទុកនេះត្រូវបានចែកជាក្រុម និង ជាប្រភេទ ។

**មាត្រា ១៤.–ថ្មី**

ចំណាយជាប្រក្រតីរបស់ថវិកា ត្រូវបានបែងចែកជា ២ ក្រុម និង ៦ ប្រភេទគឺ :

ក្រុមទី ១ : ចំណាយពិត

-ប្រភេទទី ១ : មធ្យោបាយសេវា

-ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ

-ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ

៤

-ប្រភេទទី ៤ : ចំណាយផ្សេងៗ

ក្រុមទី ២ : ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក

-ប្រភេទទី ៥ : ចំណាយតាមដីកា

-ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជា ជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៥.–ថ្មី(២)**

ចំណាយជាមូលធននៃថវិកាគឺសំរាប់ការអនុវត្តន៍កម្មវិធី ការអនុវត្តន៍គំរោងវិនិយោគ ការចូលរួមភាគកម្ម និង ការទូទាត់បំណុល ។ ចំណាយជាមូលធនត្រូវបានបែងចែកជា ២ ក្រុម និង ៣ ប្រភេទគឺ :

ក្រុមទី ១ : ចំណាយពិត

-ប្រភេទទី ១ : ការទូទាត់ប្រាក់ខ្ចី

-ប្រភេទទី ២ : អចលកម្ម

ក្រុមទី ២ : ចំណាយតាមដីកា

-ប្រភេទទី ៣ : ចំណាយតាមដីកា

ប្រភេទចំណាយនីមួយៗត្រូវបានធ្វើចំណាត់ថ្នាក់ជាជំពូក គណនី អនុគណនី និងជាយថាហេតុ អាចលំអិតជាងនេះទៀត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឥណទានវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តដោយមិនឆ្លងកាត់បរិបថថវិកាពេញលេញ គឺជាឥណទានមានលក្ខណៈជាប់ស្ទាន ហើយពុំអាចធ្វើជាកម្មវត្ថុនៃនិយ័តភាពទៅប្រភេទថវិកាណាមួយផ្សេងទៀតបានឡើយ ។

**មាត្រា ១៧.–ថ្មី(២)**

ឥណទានថវិកាដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានបែងចែកលំអិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និង គោលដៅនៃឥណទានថវិកា ។

✱

ឥណទានទាំងនេះអាចធ្វើជាកម្មវត្ថុសំរាប់ការរៀបចំថវិកាតាមកម្មវិធី និងការប្រមូលផ្តុំតាមវិស័យផងដែរ ។

ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ចំណាយជាប្រក្រតីនៃប្រភេទ ២ "បន្ទុកហិរញ្ញវត្ថុ" និងប្រភេទ ៦ " ចំណាយមិនបានគ្រោងទុក " មិនត្រូវបានបែងចែកឱ្យទៅក្រសួង ឬ ស្ថាប័នសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។

ឥណទាននេះទុកសំរាប់សងការប្រាក់នៃប្រាក់ខ្ចី ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងឥណទានត្រៀមបំរុងសំរាប់ចំណាយផ្សេងៗលើមុខសញ្ញាដែលកើតឡើងជាយថាហេតុ ។

ឥណទានត្រៀមបំរុង ត្រូវបានអនុញ្ញាតសំរាប់ការចំណាយទាំងឡាយណា ដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលដែលឥណទាននោះត្រូវបានអនុម័ត ។ ការបែងចែកឥណទានត្រៀមបំរុងទាំងនេះតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រភេទ ១ នៃចំណាយជាមូលធន គឺសំរាប់ការទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និងពីក្រៅប្រទេស និង មូលបត្រផ្សេងៗ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចីចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញ ព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និងមូលបត្រផ្សេងៗ ។

**មាត្រា ២៦-ថ្មី(២)**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំនីមួយៗ តាមប្រតិទិនដូចខាងក្រោមនេះ :

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែ មីនា ដល់ខែ ឧសភា)**

នៅសប្តាហ៍ទីមួយនៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម

ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិ សំរាប់ការអភិវឌ្ឍន៍ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់រដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង អង្គភាពក្រោមឱវាទ ដោយផ្អែកលើសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅកម្មវិធី និង ផែនការសកម្មភាពជាអាទិភាពរបស់ក្រសួង-ស្ថាប័ន និងខេត្ត-ក្រុង ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់វិស័យ និង គោលនយោបាយជាតិសំរាប់ការអភិវឌ្ឍន៍ ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

## ការរៀបចំគម្រោងថវិកា (ពីខែ មិថុនា ដល់ខែ កញ្ញា)

នៅសប្តាហ៍ទីមួយនៃខែមិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ដោយបញ្ជាក់ជូននូវទំរង់បែបបទ និងនីតិវិធីនៃការរៀបចំគំរោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និង ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ហើយផ្ញើជូនក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ដើម្បីរៀបចំគំរោងចំណូល-ចំណាយថវិកាលំអិតរបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណូល-ចំណាយថវិកាលំអិតរបស់ខ្លួន សំរាប់រដ្ឋបាលកណ្តាល មន្ទីរជំនាញ ខេត្ត-ក្រុង និង អង្គភាពក្រោមឱវាទ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគំរោងថវិកា និង អាទិភាពនៃគោលនយោបាយរបស់ខ្លួន ។ គំរោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគំរោងចំណូល-ចំណាយថវិការបស់ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័ន ព្រមទាំងអភិបាលគ្រប់ខេត្ត-ក្រុង មកពិភាក្សាការពារគំរោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគំរោងចំណូល-ចំណាយថវិកាទាំងនោះឱ្យសមស្របតាមបទប្បញ្ញត្តិនៃការណែនាំ ដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និង បង្កើនចំណូលឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការបូកសរុប ដើម្បីធ្វើតុល្យភាពចំណូល-ចំណាយថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

## ការអនុម័តថវិកា (ពីខែ តុលា ដល់ខែ ធ្នូ)

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និង ដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទីមួយនៃខែ ធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## មាត្រា ៣៥--ថ្មី

គំរោងច្បាប់ហិរញ្ញវត្ថុចែកចេញជាពីរផ្នែក ។ ផ្នែកទី ១ ច្បាប់អនុញ្ញាតឱ្យប្រមូលគ្រប់ធនធានសាធារណៈ និង កំណត់ធនធានទាំងនោះជាទឹកប្រាក់សរុប ។ ច្បាប់បានកំណត់ទិសដៅ និង មធ្យោបាយអនុវត្តចំពោះចំណាយជាមូលធន ។ ច្បាប់បានកំណត់នូវឥណទាន ត្រូវផ្តល់ខ្ពស់បំផុត ដែលជាគុណប្រយោជន៍ដល់ថវិកាទូទៅ និង គណនីពិសេសរបស់រតនាគារ ។ ច្បាប់រួមមានបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងដល់ចំណូលសារពើពន្ធ និង ទាក់ទងដល់គ្រប់បទប្បញ្ញត្តិហិរញ្ញវត្ថុផ្សេងៗទៀត ។ ផ្នែកទី ២ រួមមានតារាងកំណត់ចេញជាក្រុម ប្រភេទជំពូក គណនី និង អនុគណនី ដែលទាក់ទងដល់ចំណូលជាប្រក្រតីនៃថវិកាទូទៅ ។ ច្បាប់មានគំរោងចំណាយជាប្រក្រតីរបស់ថវិកាទូទៅ បែងចែកទៅតាមក្រសួង និង អង្គភាពសាធារណៈ

ប្រហាក់ប្រហែល ហើយបែងចែកទៅតាមប្រភេទចំណាយដែលបានអនុម័ត ។ ច្បាប់បាន កំណត់ទិសដៅ និង មធ្យោបាយអនុវត្តសំរាប់ចំណាយជាមូលធននៃថវិកា និង កម្មវិធីឥណទាន និង បែងចែកចំណាយជាមូលធនទៅតាមក្រសួង និង អង្គភាពសាធារណៈប្រហាក់ប្រហែល ជាជំពូក ដែលចែកចេញជាឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់ ។ ច្បាប់កំណត់បញ្ជី គណនីពិសេសរបស់រតនាគារដែលមានលក្ខណៈរដ្ឋបាល និង កំណត់គណនីពិសេសនីមួយៗ នូវចំនួនទឹកប្រាក់ចំណូល និង ចំនួនទឹកប្រាក់ចំណាយ ។

**មាត្រា ៣៩.–ថ្មី**

ការបែងចែកលំអិតនៅក្នុងជំពូក ជាគណនី និង អនុគណនីនៃឥណទានទាំងឡាយ ត្រូវ ប្រព្រឹត្តទៅដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៤២.–ថ្មី**

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយ នៅក្នុងជំពូកតែមួយ ត្រូវបានអនុញ្ញាតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៥៤.–ថ្មី**

រដ្ឋកាន់គណនេយ្យចំណូល-ចំណាយថវិកា និង គណនេយ្យទូទៅនៃកិច្ចប្រតិបត្តិការ ទាំងមូល ។ គណនីរបស់រដ្ឋ ត្រូវមានភាពទៀងទាត់ប្រាកដប្រជានៃបេតិកភ័ណ្ឌ និង ស្ថានភាព ហិរញ្ញវត្ថុ ។

គណនេយ្យទូទៅរបស់រដ្ឋ ត្រូវផ្អែកលើគោលការណ៍កត់ត្រាទុកមុននូវសិទ្ធិ និង កាតព្វកិច្ចប្រតិបត្តិការទាំងឡាយដែលជាប់ពាក់ព័ន្ធដោយមិនផ្អែកលើការិយបរិច្ឆេទបើកផ្តល់ ឬ ទទួលចំណូល ។

**មាត្រា ៦០.–ថ្មី**

ប្រតិបត្តិការដែលបង្ហាញដោយសេចក្តីព្រាងនៃច្បាប់ស្តីពីការទូទាត់ថវិកា ត្រូវបានណាត ក្នុងតារាងទាំងឡាយដែលបង្ហាញ :

១-ចំពោះចំណាយនៃថវិកាទូទៅ : ការគ្រោងទុកដើមដំបូង ការអនុញ្ញាតថ្មីនិង បញ្ជាចំណាយ បែងចែកតាមក្រសួង ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

២-ចំពោះចំណូល : ការគ្រោងទុកដើមដំបូង ព្រមទាំងការកែប្រែ និង ការប្រមូល ដែលញែកតាមក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី ។

៣-ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និង ចំណាយ និងការកែប្រែ ដែលបានធ្វើប្រសិនជាមាន ជាមួយនឹងសមិទ្ធកម្មសំរាប់ថវិការបស់រដ្ឋបាល សាធារណៈនីមួយៗ ។

**មាត្រា ២.-**

ការអនុវត្តន៍ថវិកា និង ការទូទាត់ថវិកាសំរាប់បណ្តាឆ្នាំមុនឆ្នាំ ២០០៧ ត្រូវអនុវត្តទៅ តាមមាតិកាថវិកា និង មាតិកាគណនេយ្យដូចដែលបានអនុម័តថវិកា ។ ការរៀបចំថវិកា ការ អនុវត្តន៍ថវិកា និង ការទូទាត់ថវិកាសំរាប់ឆ្នាំ ២០០៧ និង ឆ្នាំបន្តបន្ទាប់ត្រូវធ្វើទៅតាមមាតិកា ថវិកា និងមាតិកាគណនេយ្យដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

## ផ្នែកទី ២

## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា ៣.-**

មាត្រា ៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចខាង ក្រោម :

**មាត្រា ៣០.-ថ្មី**

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារ តាមទីក្រុង និង តាមតំបន់នីមួយៗ ដែល វាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិន បានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំប្រមូលពន្ធ ។

**មាត្រា ៤.-ថ្មី**

មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម :

**មាត្រា ៧.-ថ្មី**

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល និង សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬ ទ្រព្យវិនិយោគ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម ។ និយមន័យនៃពាក្យ"អចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ទ្រព្យវិនិយោគ ការសម្រេចបាន" ព្រមទាំងការកំណត់មូលដ្ឋានគិតពន្ធ វិធាន និងនីតិវិធីនៃការប្រមូល ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

រូបវន្តបុគ្គល និង នីតិបុគ្គល ដែលប្រកបសេវាកម្មវាយតម្លៃ និង ជួញដូរអចលនទ្រព្យ ត្រូវមានវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិធាន និងនីតិវិធី ក្នុងការចេញវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី ៣

## បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

**មាត្រា ៦.-**

មាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៧.–ថ្មី**

ចំណូលនៃថវិកាខេត្ត-ក្រុងរួមមានចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ដែលបានផ្ទេរពីថវិការដ្ឋ ឬ បង្កើតឡើងដោយច្បាប់ដោយឡែក ។ ខេត្ត-ក្រុងគ្មានសិទ្ធិសំរេចក្នុងការខ្ចីទេ ។

១-ត្រូវបានផ្ទេរពីថវិការដ្ឋទៅថវិកាខេត្ត-ក្រុង នូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដូចតទៅ :

**ក/ចំណូលសារពើពន្ធ :**

- ពន្ធប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- អាករសំរាប់បំភ្លឺសាធារណៈ (អាករបន្ថែមលើស្រា និងបារី)
- អាករលើការស្នាក់នៅ
- ពន្ធសត្តឃាដ
- ពន្ធប៉ាតង់
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

**ខ/ចំណូលមិនមែនសារពើពន្ធ :**

- សម្បទានពីរ៉ែ
- ការជួលកន្លែងលក់ដូរក្នុងទីផ្សារ
- ចំណូលពីភាស៊ីផ្សារ
- ចំណូលពីចំណតរថយន្ត
- ចំណូលពីចំណតជលយាន
- ចំណូលពីសត្តឃាដដ្ឋាន
- ចំណូលពីកំពង់ចំលង

ﾀ

-ចំណូលពីកន្លែងប្រមូលផ្តុំ ដើម្បីបែងចែកនូវផលិតផលដោយខ្សែក (ត្រី ផ្លែឈើ បន្លែ.....)

-ផលទុននៃរដ្ឋាករទឹក

-ផលទុននៃការផ្គត់ផ្គង់អគ្គិសនី

២-មាតិកានៃចំណូលផ្ទាល់ពីចំណូលសារពើពន្ធ សំរាប់ជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ត្រូវបង្កើតឡើងដោយច្បាប់ដោយឡែក ។

៣-មាតិកានៃចំណូលផ្ទាល់ពីចំណូលមិនមែនសារពើពន្ធសំរាប់ជាគុណប្រយោជន៍របស់ខេត្ត-ក្រុង មានដូចតទៅ :

ក-ចំណូលពីការប្រើអំណាចរដ្ឋបាល របស់ខេត្ត-ក្រុង (ទម្រង់ការរដ្ឋបាលអនុញ្ញាតរដ្ឋបាល......)

ខ-ចំណូលពីសេវាសាធារណៈរបស់ខេត្ត-ក្រុង (សេវាផ្ទាល់សេវាសហប្រតិបត្តិការ........)

ចំណូលទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមការឯកភាពរបស់ក្រសួងពាក់ព័ន្ធ ដែលនឹងត្រូវបែងចែកជាតារាងចំណូលជាអតិបរមា ។

គ-ផលទុននៃទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ខេត្ត-ក្រុង

ប្រភេទចំណូលដូចបានចែងក្នុងចំណុចទី ១ ទី ២ និងទី ៣ ខាងលើត្រូវបានបែងចែកជាជំពូក គណនី និងអនុគណនី ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៨._ថ្មី**

គំរោងថវិការបស់ខេត្ត-ក្រុង ត្រូវបានរៀបចំឡើងដោយអភិបាលខេត្ត-ក្រុង ទៅតាមនីតិវិធី ដែលបានកំណត់ដោយសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នៅសប្តាហ៍ទី ១ ខែ មិថុនា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើជូនខេត្ត-ក្រុង នូវសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកានៃឆ្នាំបន្ទាប់ ដើម្បីខេត្ត-ក្រុង រៀបចំគំរោងចំណូល-ចំណាយថវិការបស់ខ្លួន ។

គំរោងថវិការបស់ខេត្ត-ក្រុង ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា នៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុ ដែលបង្ហាញអំពីការវិភាគគោលដៅនៃកម្មវិធី និងថវិតលក្ខណៈនៃថវិកានោះ ។

គំរោងថវិការបស់ខេត្ត-ក្រុងទាំងអស់ គឺជាកញ្ចប់ថវិកាមួយ ដែលត្រូវបញ្ជូនមកសុំរដ្ឋសភាពិនិត្យអនុម័តយល់ព្រមក្នុងក្របខ័ណ្ឌថវិកាទូទៅរបស់រដ្ឋ និងត្រូវរក្សានូវតុល្យភាពសេដ្ឋកិច្ចជាមូលដ្ឋាន ។ ការបែងចែកកញ្ចប់ថវិកានេះទៅតាមខេត្ត-ក្រុងនីមួយៗត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ២
## ចំណូល_ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ៧._**

ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ២០០៧ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និង ចំណូលនានា ព្រមទាំងធ្វើឱ្យសំរេចនូវអំណោយ មូលនិធិបដិភាគ និង ធនធានបានមកពីការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង “ក” ដែលភ្ជាប់មកជាមួយច្បាប់នេះក្នុងទឹកប្រាក់សរុបចំនួន ៤.៦២២.៣០៥,៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណូលចរន្ត..............................៣.២៥២.១៧២,៥ លានរៀល

-ចំណូលជាមូលធន.........................១.៣៧០.១៣៣ លានរៀល

+ ចំណូលជាមូលធនក្នុងប្រទេស...............៣០.០០០ លានរៀល

+ ចំណូលជាមូលធនក្រៅប្រទេស.........១.៣៤០.១៣៣ លានរៀល

**មាត្រា ៨._**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសំរាប់

ᯤ

ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ស្មើនឹង ៤.៦២២.៣០៥,៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណាយចរន្ត..............................២.៨៣៧.១៧២,៥ លានរៀល

-ចំណាយជាមូលធន...........................១.៧៨៥.១៣៣ លានរៀល

\+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស...៥៧៥.១៣៣ លានរៀល

\+ ដោយមូលនិធិថវិកា[១] .......................៣៤៥.០០០ លានរៀល

\+ ដោយមូលនិធិទ្រទ្រង់ថវិកា................២៣០.១៣៣ លានរៀល

\+ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់[២]

..................................១.១១០.០០០ លានរៀល

\+ ការទូទាត់ប្រាក់កម្ចី.............................១០០.០០០ លានរៀល

**មាត្រា ៩.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកាសំរាប់ចំណាយចរន្តរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ស្មើនឹង ២.៨៣៧.១៧២,៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទនៃថវិកា ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ១០.-**

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសំរាប់ការគ្រប់គ្រងពីឆ្នាំ ២០០៧ ដល់ ២០០៩ ត្រូវបានកំណត់ស្មើនឹង ៧.៤០៤.៨០៨ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគំរោង និង តាមឆ្នាំ ដូចមានចែងក្នុងតារាង "គ$_1$-គ$_2$-គ$_3$" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

---

[១] រួមមានគំរោងវិនិយោគ ២២០.០០០ លានរៀល និង បរិភោគ ១២៥.០០០ លានរៀល

[២] វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ហើយចំនួនទឹកប្រាក់នេះមិនឆ្លងកាត់រតនាគារទេ ។

**មាត្រា ១១.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ដូចតទៅ :

-ឥណទានភ្ជាប់សន្យា..........................២.៥៨២.០៣៣ លានរៀល

-ឥណទានទូទាត់..............................១.៧៨៥.១៣៣ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-ឥណទានភ្ជាប់សន្យា............................៥៧៥.១៣៣ លានរៀល

-ឥណទានទូទាត់................................៥៧៥.១៣៣ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ :

-ឥណទានភ្ជាប់សន្យា..........................១.៩០៦.៩០០ លានរៀល

-ឥណទានទូទាត់..............................១.១១០.000 លានរៀល

គ. ការទូទាត់ប្រាក់កម្ចី :

-ឥណទានភ្ជាប់សន្យា............................១០០.០០០ លានរៀល

-ឥណទានទូទាត់................................១០០.000 លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ១២.-**

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលបានរៀបចំឡើងដោយតារាង "ក" ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង "ខ" ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ :

-/-

ឯកតា:លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+) /ឱនភាព(-) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ៣.២៨២.១៧២,៥ | |
| ១. ចំណូលចរន្ត | ៣.២៥២.១៧២,៥ | |
| ២. ចំណូលជាមូលធនក្នុងប្រទេស | ៣០.០០០ | |
| II. សរុបចំណាយថវិកា | ៤.៥២២.៣០៥,៥ | |
| ១. ចំណាយចរន្ត | ២.៨៣៧.១៧២,៥ | |
| ២. ចំណាយជាមូលធន[៣] | ១.៦៨៥.១៣៣ | |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៥៧៥.១៣៣ | |
| + ដោយមូលនិធិថវិកា | ៣៤៥.០០០ | |
| -គំរោងវិនិយោគ | ២២០.០០០ | |
| -បរិភាគ | ១២៥.០០០ | |
| + វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា[៤] | ២៣០.១៣៣ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ១.១១០.០០០ | |
| អតិរេកនៃថវិកាចរន្ត (I.១ -II.១ ) | | +៤១៥.០០០ |
| ឱនភាពសរុបនៃថវិកាទូទៅ (I-II ) | | -១.២៤០.១៣៣ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +១.២៤០.១៣៣ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +១.២៤០.១៣៣ |
| - មូលនិធិទ្រទ្រង់ថវិកា | | +២៣០.១៣៣ |
| - មូលនិធិវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | | +១.១១០.០០០ |
| - ការទូទាត់ប្រាក់កម្ចី | | -១០០.០០០ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | |
| - ហិរញ្ញប្បទានធនាគារជាតិ | | |

[៣] មិនគិតការវិលសំចំណូល ១០០.០០០លានរៀល ដែលមានកំណត់នៅក្នុងសារប័ត្រ III (ហិរញ្ញប្បទាននៃឱនភាព)

[៤] គំរោងទាំងអស់ត្រូវសុំការយល់ព្រមចំណាយពីដៃគូអភិវឌ្ឍន៍ជាមុន ។

## ជំពូកទី ៣

## ការខ្ចី និង ការធានារបស់រដ្ឋ

**មាត្រា ១៣.-**

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេមានកំរិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលានអេសដេអ៊ែ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍នៃការខ្ចី និង ការធានានេះ ជូនរដ្ឋសភា និង ព្រឹទ្ធសភា រៀងរាល់ ៦ ខែ ម្តង ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ ដែលមានស្តុកចំនួន ១០០.០០០.០០០.០០០៛ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយនូវតំរូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

**មាត្រា ១៤.-**

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសង

⁂

បំណុលតាមកាលកំណត់ ឬ តាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង លក្ខខណ្ឌទាំងឡាយ ដែលច្បាប់នេះបានកំណត់នោះទេ ។

## ជំពូកទី ៤

## ថវិការបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

**មាត្រា ១៥.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ កញ្ចប់ថវិការួមនៃ ថវិការបស់ខេត្ត-ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

សរុបចំណូលថវិកា..........................................១៦៨.៤០០ លានរៀល

-សរុបចំណូលចរន្ត..................................១៦៨.៤០០ លានរៀល

+ ចំណូលសារពើពន្ធ..............................៩៦.៤៥៤ លានរៀល

+ ចំណូលមិនមែនសារពើពន្ធ.....................២១.៩៤៦ លានរៀល

+ ចំណូលឧបត្ថម្ភពីថវិការដ្ឋ.......................៥០.០០០ លានរៀល

-ចំណូលជាមូលធន..........................................០ លានរៀល

+ ចំណូលជាមូលធនផ្ទៃក្នុង..............................០ លានរៀល

+ ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ...........០ លានរៀល

សរុបចំណាយថវិកា......................................១៦៨.៤០០ លានរៀល

-ចំណាយចរន្ត....................................១៣៤.៦២២ លានរៀល

-ចំណាយជាមូលធន..............................៣៣.៧៧៨ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត-ក្រុងនីមួយៗក៏ដូចជាការបែងចែកឥណ- ទាននៅផ្ទៃក្នុងថវិកានេះជា ជំពូក គណនី និង អនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋ- មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្ដីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

នស.០៦១២.៥៥៥

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ : ៤៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ២០០៦ | ច្បាប់ហិរញ្ញវត្ថុ ២០០៧ | ២០០៧/២០០៦ កើន (+) / ថយ (-) | ២០០៧/២០០៦ ភាគរយ |
|---|---|---|---|---|---|---|---|
| | | | សរុបរួមចំណូលថវិកា (I+II) | 3.814.125,0 | 4.622.305,5 | 808.180,5 | 21,19% |
| | | | I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ) | 2.956.325,0 | 3.512.305,5 | 555.980,5 | 18,81% |
| | | | ក្នុងនោះ ចំណូលក្នុងប្រទេស | 2.812.720,0 | 3.282.172,5 | 469.452,5 | 16,69% |
| | | | ក. សរុបចំណូលចរន្ត (ក្រុ១+ក្រុ២) | 2.780.720,0 | 3.252.172,5 | 471.452,5 | 16,95% |
| | | | ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | 2.780.720,0 | 3.252.172,5 | 471.452,5 | 16,95% |
| | | | ប្រភេទទី១: ចំណូលសារពើពន្ធ | 2.224.053,0 | 2.682.000,0 | 457.947,0 | 20,59% |
| 70 | | | ចំណូលសារពើពន្ធក្នុងប្រទេស | 1.495.949,0 | 1.857.540,0 | 361.591,0 | 24,17% |
| | 700 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន រូបវ័ន្តបុគ្គល | 52.600,0 | 72.200,0 | 19.600,0 | 37,26% |
| | | 7001 | ពន្ធលើប្រាក់បៀវត្ស | 37.600,0 | 52.000,0 | 14.400,0 | 38,30% |
| | | 7002 | ពន្ធលើផលទុនលើដីធ្លីផ្ទះសំបែង | 15.000,0 | 20.200,0 | 5.200,0 | 34,67% |
| | 701 | | ពន្ធលើផលទុន ប្រាក់ចំណេញ និងកំរៃទុន នីតិបុគ្គល | 152.000,0 | 267.700,0 | 115.700,0 | 76,12% |
| | | 7011 | ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 15.000,0 | 26.700,0 | 11.700,0 | 78,00% |
| | | 7012 | ពន្ធលើប្រាក់ចំណេញសហគ្រាសឯកជន | 137.000,0 | 241.000,0 | 104.000,0 | 75,91% |
| | | 7013 | ពន្ធលើផលទុនលើដីធ្លីផ្ទះសំបែង | 0,0 | 0,0 | 0,0 | |
| | 702 | | ពន្ធទូទៅលើទ្រព្យសម្បត្តិ និង សេវា | 814.342,0 | 976.650,0 | 162.308,0 | 19,93% |
| | | 7021 | អាករលើផលរបរ របបផ្ទៃក្នុង សហគ្រាសសាធារណៈ | 7,0 | 5,0 | -2,0 | -28,57% |
| | | 7022 | អាករលើផលរបរ របបផ្ទៃក្នុង សហគ្រាសឯកជន | 10.293,0 | 14.445,0 | 4.152,0 | 40,34% |
| | | 7023 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង-សហគ្រាសសាធារណៈ | 16.000,0 | 17.000,0 | 1.000,0 | 6,25% |
| | | 7024 | អាករលើតំលៃបន្ថែម-របបផ្ទៃក្នុង-សហគ្រាសឯកជន | 221.000,0 | 322.560,0 | 101.560,0 | 45,95% |
| | | 7025 | អាករលើតំលៃបន្ថែម-របបនាំចូល-សហគ្រាសប្រេងឥន្ធនៈ | 152.145,0 | 151.620,0 | -525,0 | -0,35% |
| | | 7026 | អាករលើតំលៃបន្ថែម-របបនាំចូល-សហគ្រាសផ្សេងៗទៀត | 414.897,0 | 471.020,0 | 56.123,0 | 13,53% |
| | 703 | | ពន្ធលើទ្រព្យសម្បត្តិបានកំណត់ | 419.419,0 | 449.800,0 | 30.381,0 | 7,24% |
| | | 7031 | អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង | 68.600,0 | 70.900,0 | 2.300,0 | 3,35% |
| | | 7032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល សហគ្រាសប្រេងឥន្ធនៈ | 0,0 | 113.650,0 | 113.650,0 | !!! |
| | | 7033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល សហគ្រាសផ្សេងៗទៀត | 350.819,0 | 265.250,0 | -85.569,0 | -24,39% |
| | 704 | | អាករលើសេវាដែលបានកំណត់ | 53.088,0 | 83.800,0 | 30.712,0 | 57,85% |
| | | 7041 | អាករលើកាស៊ីណូ | 50.000,0 | 62.210,0 | 12.210,0 | 24,42% |
| | | 7042 | អាករលើឆ្នោត | 3.088,0 | 2.650,0 | -438,0 | -14,18% |
| | | 7043 | អាករលើល្បែងភ្នាល់ផ្សេងៗ | 0,0 | 1.140,0 | 1.140,0 | !!! |
| | | 7048 | អាករពិសេសលើសេវាមួយចំនួនផ្សេងៗទៀត | 0,0 | 17.800,0 | 17.800,0 | !!! |
| | 708 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 4.500,0 | 7.390,0 | 2.890,0 | 64,22% |
| | | 7081 | ពន្ធតែមប្រ៉ិ | 1.700,0 | 2.490,0 | 790,0 | 46,47% |
| | | 7082 | ការផាកពិន័យនិងទោសបញ្ញត្តិសារពើពន្ធ | 2.800,0 | 4.900,0 | 2.100,0 | 75,00% |

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៧/២០០៦ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៦ | ២០០៧ | កើន (+) / ថយ (-) | ភាគរយ |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 728.104,0 | 824.460,0 | 96.356,0 | 13,23% |
| | 710 | | ពន្ធ និង អាករលើការនាំចូល | 671.759,0 | 748.870,0 | 77.111,0 | 11,48% |
| | | 7101 | ពន្ធគយពីការនាំចូល | 338.422,0 | 407.820,0 | 69.398,0 | 20,51% |
| | | 7102 | កំរៃយកមុនពីការងារគយក្នុងការនាំចូល | 29.463,0 | 35.500,0 | 6.037,0 | 20,49% |
| | | 7103 | ពន្ធគយលើផលិតផលតេលសិលា | 171.533,0 | 176.480,0 | 4.947,0 | 2,88% |
| | | 7104 | អាករបន្ថែមលើផលិតផលតេលសិលាសំរាប់ថែទាំផ្លូវថ្នល់ | 125.580,0 | 118.240,0 | -7.340,0 | -5,84% |
| | | 7105 | ផលនៃការលក់ផ្នែកគយ | 965,0 | 180,0 | -785,0 | -81,35% |
| | | 7106 | ពិន័យផ្សេងៗលើការនាំចូល | 5.796,0 | 10.650,0 | 4.854,0 | 83,75% |
| | 711 | | ពន្ធ និង អាករលើការនាំចេញ | 56.345,0 | 75.590,0 | 19.245,0 | 34,16% |
| | | 7111 | អាករលើការនាំចេញឈើ | 2.508,0 | 3.195,0 | 687,0 | 27,39% |
| | | 7112 | អាករលើការនាំចេញកៅស៊ូ | 18.193,0 | 16.330,0 | -1.863,0 | -10,24% |
| | | 7113 | អាករលើការនាំចេញផលិតផលកសិផលផ្សេងៗ | 644,0 | 1.065,0 | 421,0 | 65,37% |
| | | 7114 | កំរៃគ្រប់គ្រងការនាំចេញ | 35.000,0 | 55.000,0 | 20.000,0 | 57,14% |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 556.667,0 | 570.172,5 | 13.505,5 | 2,43% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 58.757,3 | 67.406,1 | 8.648,8 | 14,72% |
| | 720 | | ផលនៃការជួលដីធ្លី | 47.352,8 | 34.667,4 | -12.685,4 | -26,79% |
| | | 7201 | សម្បទាននេសាទ | 9.680,0 | 8.300,0 | -1.380,0 | -14,26% |
| | | 7202 | សម្បទានព្រៃឈើ | 33.000,0 | 20.000,0 | -13.000,0 | -39,39% |
| | | 7204 | សម្បទានរ៉ែ | 2.420,0 | 1.938,6 | -481,4 | -19,89% |
| | | 7205 | ការជួលដីទំនេរ | 2.252,8 | 4.428,8 | 2.176,0 | 96,59% |
| | 721 | | ផលទុនពីសហគ្រាសសាធារណៈ | 11.404,5 | 32.738,7 | 21.334,2 | 187,07% |
| | | 7212 | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 11.403,0 | 32.738,0 | 21.335,0 | 187,10% |
| | | 7213 | ការបង់ប្រាក់រំលស់ | 1,5 | 0,7 | -0,8 | -53,33% |
| 73 | | | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា | 457.881,7 | 403.019,8 | -54.861,9 | -11,98% |
| | 730 | | សហគ្រាសសាធារណៈ រដ្ឋបាល និង សេវាដំណើរការ ( រកចំណេញ) | 276.993,9 | 230.272,2 | -46.721,7 | -16,87% |
| | | 7301 | ផលទុនរបស់អាកាសចរស៊ីវិល | 50.000,0 | 50.020,0 | 20,0 | 0,04% |
| | | 7303 | ផលទុនពីសកម្មភាពទេសចរណ៍ | 75.036,5 | 84.262,0 | 9.225,5 | 12,29% |
| | | 7304 | ផលទុននៃសកម្មភាពវប្បធម៌ | 1.000,0 | 1.130,0 | 130,0 | 13,00% |
| | | 7305 | ផលទុនពីប្រៃសណីយ៍និងទូរគមនាគមន៍ | 120.000,0 | 91.853,0 | -28.147,0 | -23,46% |
| | | 7306 | ផលទុនពីវិទ្យុទូរទស្សន៍ | 1.263,8 | 1.088,0 | -175,8 | -13,91% |
| | | 7307 | ផលទុននៃរដ្ឋាករទឹក | 15,0 | 10,0 | -5,0 | -33,33% |
| | | 7308 | ផលទុនផ្សេងៗទៀត | 29.678,6 | 1 [illegible]9,2 | -27.759,4 | -93,57% |

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ក"

## ចំណូលថវិកាជាតិរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៧/២០០៦ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៦ | ២០០៧ | កើន (+) / ថយ (-) | ភាគរយ |
| 73 | 731 | | រដ្ឋបាល និង សេវា ( មិនរកចំណេញ ) | 9.996,0 | 9.816,1 | -179,9 | -1,80% |
| | | 7311 | ការលក់សំភារៈបរិក្ខារ ,សំភារៈខូចខាត ,សំភារៈសិក្សា | 505,0 | 325,0 | -180,0 | -35,64% |
| | | 7312 | លក់ឯកសារ,លតាប័ត្រ,និងលិខិតបោះពុម្ពផ្សេងៗ | 8.925,0 | 8.883,5 | -41,5 | -0,46% |
| | | 7313 | ផលនៃការដឹកជញ្ជូនទំនិញ | 15,0 | 8,9 | -6,1 | -40,67% |
| | | 7315 | កំរៃនៃការថែទាំ | 551,0 | 598,7 | 47,7 | 8,66% |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 125.559,9 | 134.827,2 | 9.267,3 | 7,38% |
| | | 7321 | អាករស្នាមទូត( ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ ) | 103.400,0 | 106.080,0 | 2.680,0 | 2,59% |
| | | 7323 | ផលលើការបង្កើតសហគ្រាស | 400,0 | 540,0 | 140,0 | 35,00% |
| | | 7324 | ផលពីការបង់សិទ្ធប្រឡង | 240,0 | 253,0 | 13,0 | 5,42% |
| | | 7325 | ផលពីការលក់ផ្លាកលេខ | 1.650,0 | 1.747,0 | 97,0 | 5,8?% |
| | | 7326 | ចំណូលពីប្រដាប់គ្តី | 490,0 | 338,0 | -152,0 | -31,02% |
| | | 7327 | សេវាសុរិយោដី និង សេវាសំណង់ | 2.300,0 | 3.840,0 | 1.540,0 | 66,96% |
| | | 7328 | ផលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន | 17.079,9 | 22.029,2 | 4.949,3 | 28,98% |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | 45.331,9 | 28.104,3 | -17.227,6 | -38,00% |
| | | 7331 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល | 18.575,0 | 8.320,0 | -10.255,0 | -55,21% |
| | | 7332 | ការជួលសហគ្រាសសាធារណៈនៅខេត្តក្រុង ( មន្ទីរជំនាញ ) | 3,5 | 2,4 | -1,1 | -31,43% |
| | | 7333 | ការជួលសំភារៈនិងមធ្យោបាយដឹកជញ្ជូន | 5,0 | 2,5 | -2,5 | -50,00% |
| | | 7334 | ការជួលអចលនវត្ថុ ( អសង្ហារិម ) | 26.748,4 | 19.779,4 | -6.969,0 | -26,05% |
| 74 | | | **ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម** | 28,0 | 50,0 | 22,0 | 78,57% |
| | 741 | | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | 28,0 | 50,0 | 22,0 | 78,57% |
| 77 | | | **ផលផ្សេងៗ និង ផលពិសេស** | 40.000,0 | 99.696,6 | 59.696,6 | 149,24% |
| | 772 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 40.000,0 | 93.454,6 | 53.454,6 | 133,64% |
| | 775 | | ផលពីការលក់អចលនវត្ថុ ( ការលក់ទ្រព្យសម្បត្តិរដ្ឋ ) | 0,0 | 6.242,0 | 6.242,0 | !!! |
| | | | **ខ. សរុបចំណូលជាមូលធន (ក្រ១+ក្រ២)** | 175.605,0 | 260.133,0 | 84.528,0 | 48,14% |
| | | | **ក្រុមទី១:ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | 175.605,0 | 260.133,0 | 84.528,0 | 48,14% |
| | | | **ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់** | 32.000,0 | 30.000,0 | -2.000,0 | -6,25% |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | 32.000,0 | 30.000,0 | -2.000,0 | -6,25% |
| | 271 | | ការអោយខ្ចី ( ការសងវិញនូវមូលធន ) | 32.000,0 | 30.000,0 | -2.000,0 | -6,25% |
| | | | **ប្រភេទទី២: ចំណូលពីប្រភពខាងក្រៅ** | 143.605,0 | 230.133,0 | 86.528,0 | 60,25% |
| 13 | | | **ឧបត្ថម្ភធនវិនិយោគ** | 66.778,0 | 86.633,0 | 19.855,0 | 29,73% |
| | 131 | | ឧបត្ថម្ភធនទទួលសំភារៈបរិក្ខារ-ទ្វេភាគី | 66.778,0 | 20.500,0 | -46.278,0 | -69,30% |
| | | 1311 | ជប៉ុន | 66.778,0 | 20.500,0 | -46.278,0 | -69,30% |
| | 132 | | ឧបត្ថម្ភធនទទួលសំភារៈបរិក្ខាពីអង្គការអន្តរជាតិ | 0,0 | 66.133,0 | 66.133,0 | !!! |

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ២០០៧/២០០៦ | |
|---|---|---|---|---|---|---|---|
| | | | | ២០០៦ | ២០០៧ | កើន (+) / ថយ (-) | ភាគរយ |
| 13 | 132 | 1328 | ផ្សេងៗ | 0,0 | 66.133,0 | 66.133,0 | !!! |
| 16 | | | ការខ្ចី និង ចំណូលប្រហាក់ប្រហែល | 76.827,0 | 143.500,0 | 66.673,0 | 86,78% |
| | 162 | | ការខ្ចីក្រៅប្រទេស | 76.827,0 | 143.500,0 | 66.673,0 | 86,78% |
| | | 1621 | ពហុភាគី | 76.827,0 | 143.500,0 | 66.673,0 | 86,78% |
| | | | II. សរុបចំណូលជាមូលធនអនុវត្តក្រៅរតនាគារជាតិ | 857.800,0 | 1.110.000,0 | 252.200,0 | 29,40% |
| | | | ប្រភពទី២: ចំណូលពីប្រភពខាងក្រៅ | 857.800,0 | 1.110.000,0 | 252.200,0 | 29,40% |
| 13 | | | ឧបត្ថម្ភធនវិនិយោគ | 457.500,0 | 592.000,0 | 134.500,0 | 29,40% |
| | 131 | | ឧបត្ថម្ភធនទទួលពីសំភារៈបរិក្ខារ-ទ្វេភាគី | 457.500,0 | 592.000,0 | 134.500,0 | 29,40% |
| | | 1311 | ជប៉ុន | 42.000,0 | 0,0 | -42.000,0 | -100,00% |
| | | 1318 | ផ្សេងៗ | 415.500,0 | 592.000,0 | 176.500,0 | 42,48% |
| 16 | | | ការខ្ចី និង ចំណូលប្រហាក់ប្រហែល | 400.300,0 | 518.000,0 | 117.700,0 | 29,40% |
| | 162 | | ការខ្ចីក្រៅប្រទេស | 400.300,0 | 518.000,0 | 117.700,0 | 29,40% |
| | | 1621 | ពហុភាគី | 400.300,0 | 518.000,0 | 117.700,0 | 29,40% |

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ខ"

ទំព័រ១/៣

## ចំណាយថវិកាជូនទៅរបស់រដ្ឋ

ឯកតា:លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទទី ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៥ ចំណាយតាមដីកា | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| **សរុបរួមចំណាយ** | **4.622.305,5** | **2.837.172,5** | **1.961.190,7** | **50.000,0** | **443.058,7** | **957,0** | **50,0** | **381.916,1** | **1.785.133,0** | **100.000,0** | **1.685.133,0** |
| រដ្ឋបាលកណ្តាល | 3.927.519,5 | 2.142.386,5 | 1.300.540,7 | 50.000,0 | 408.963,7 | 916,0 | 50,0 | 381.916,1 | 1.785.133,0 | 100.000,0 | 1.685.133,0 |
| មន្ទីរជំនាញខេត្ត-ក្រុង | 694.786,0 | 694.786,0 | 660.650,0 | | 34.095,0 | 41,0 | | | | | |
| **ក. វិស័យរដ្ឋបាលទូទៅ** | **402.756,4** | **402.756,4** | **315.409,9** | | **87.005,5** | **291,0** | **50,0** | | | | |
| រដ្ឋបាលកណ្តាល | 378.425,4 | 378.425,4 | 291.081,9 | | 87.002,5 | 291,0 | 50,0 | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 24.331,0 | 24.331,0 | 24.328,0 | | 3,0 | | | | | | |
| ០១. ព្រះបរមរាជវាំង | 41.500,0 | 41.500,0 | 21.748,0 | | 19.712,0 | 40,0 | | | | | |
| ០២. រដ្ឋសភា | 67.000,0 | 67.000,0 | 64.276,0 | | 2.724,0 | | | | | | |
| ០៣. ព្រឹទ្ធសភា | 23.100,0 | 23.100,0 | 21.615,0 | | 1.485,0 | | | | | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 3.450,0 | 3.450,0 | 3.423,0 | | 25,0 | 2,0 | | | | | |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 85.000,0 | 85.000,0 | 29.300,0 | | 55.600,0 | 100,0 | | | | | |
| ០៥.២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | 1.870,0 | 1.870,0 | 1.870,0 | | | | | | | | |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 4.279,0 | 4.279,0 | 4.224,0 | | 6,0 | 49,0 | | | | | |
| ០៧. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 26.500,0 | 26.500,0 | 24.639,0 | | 1.861,0 | | | | | | |
| ២. រដ្ឋបាលកណ្តាល | 26.500,0 | 26.500,0 | 24.639,0 | | 1.861,0 | | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | | | | | | | | | | | |
| ០៨.ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | 7.620,0 | 7.620,0 | 7.602,0 | | | 18,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 4.690,0 | 4.690,0 | 4.672,0 | | | 18,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 2.930,0 | 2.930,0 | 2.930,0 | | | | | | | | |
| ០៩. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 60.100,0 | 60.100,0 | 59.519,0 | | 564,0 | 17,0 | | | | | |
| ១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | 44.487,0 | 44.487,0 | 39.397,0 | | 5.000,0 | 40,0 | 50,0 | | | | |
| ១ រដ្ឋបាលកណ្តាល | 37.987,0 | 37.987,0 | 32.897,0 | | 5.000,0 | 40,0 | 50,0 | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 6.500,0 | 6.500,0 | 6.500,0 | | | | | | | | |
| ១៤. ក្រសួងផែនការ | 9.500,0 | 9.500,0 | 9.487,0 | | 13,0 | | | | | | |
| ១. រដ្ឋបាលកណ្តាល | 5.100,0 | 5.100,0 | 5.090,0 | | 10,0 | | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 4.400,0 | 4.400,0 | 4.397,0 | | 3,0 | | | | | | |
| ២៦. ក្រសួងយុត្តិធម៌ | 18.837,0 | 18.837,0 | 18.822,0 | | 9,0 | 6,0 | | | | | |
| ១. យុត្តធម៌ | 4.603,0 | 4.603,0 | 4.598,0 | | | 5,0 | | | | | |
| ២. តុលាការកំពូល | 1.518,0 | 1.518,0 | 1.508,0 | | 9,0 | 1,0 | | | | | |
| ៣. សាលាឧទ្ធរណ៍ | 1.320,0 | 1.320,0 | 1.320,0 | | | | | | | | |
| ៤. ក្រុមប្រឹក្សាអង្គចៅក្រម | 895,0 | 895,0 | 895,0 | | | | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 10.501,0 | 10.501,0 | 10.501,0 | | | | | | | | |
| ៣០. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត | 3.729,4 | 3.729,4 | 3.710,9 | | 1,5 | 17,0 | | | | | |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 5.784,0 | 5.784,0 | 5.777,0 | | 5,0 | 2,0 | | | | | |
| **ខ. វិស័យការពារជាតិ និង សន្តិសុខ** | **507.330,0** | **507.330,0** | **491.938,0** | | **15.392,0** | | | | | | |
| ០៦. ក្រសួងការពារជាតិ | 320.500,0 | 320.500,0 | 312.700,0 | | 7.800,0 | | | | | | |
| ០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 186.830,0 | 186.830,0 | 179.238,0 | | 7.592,0 | | | | | | |
| **គ. វិស័យសង្គមកិច្ច** | **1.105.296,0** | **1.105.296,0** | **926.127,8** | | **178.887,2** | **281,0** | | | | | |
| រដ្ឋបាលកណ្តាល | 513.432,0 | 513.432,0 | 358.966,8 | | 154.216,2 | 249,0 | | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 591.864,0 | 591.864,0 | 567.161,0 | | 24.671,0 | 32,0 | | | | | |
| ១១. ក្រសួងព័ត៌មាន | 19.113,0 | 19.113,0 | 19.069,0 | | 31,0 | 13,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 14.613,0 | 14.613,0 | 14.569,0 | | 31,0 | 13,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 4.500,0 | 4.500,0 | 4.500,0 | | | | | | | | |
| ១២. ក្រសួងសុខាភិបាល | 336.926,0 | 336.926,0 | 198.408,0 | | 138.411,0 | 107,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 238.576,0 | 238.576,0 | 103.929,0 | | 134.561,0 | 86,0 | | | | | |
| ៥. មន្ទីរជំនាញខេត្ត-ក្រុង | 98.350,0 | 98.350,0 | 94.479,0 | | 3.850,0 | 21,0 | | | | | |

## ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ខ"

ទំព័រ២/៣

## ចំណាយថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយចរន្ត | ប្រភេទ ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៥ ចំណាយភាគជីកា | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុប ចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ១៦. ក្រសួងអប់រំ យុវជន និង កីឡា | 546.000,0 | 546.000,0 | 532.245,8 | | 13.656,2 | 98,0 | | | | | |
| ១. អប់រំ | 163.000,0 | 163.000,0 | 157.099,8 | | 5.810,2 | 90,0 | | | | | |
| ២. ឧត្តមសិក្សា | 19.000,0 | 19.000,0 | 18.599,0 | | 401,0 | | | | | | |
| ៣. យុវជន និង កីឡា | 16.000,0 | 16.000,0 | 14.055,0 | | 1.945,0 | | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុងនានា | 348.000,0 | 348.000,0 | 342.492,0 | | 5.500,0 | 8,0 | | | | | |
| ១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 18.900,0 | 18.900,0 | 17.614,0 | | 1.276,0 | 10,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 12.300,0 | 12.300,0 | 11.017,0 | | 1.273,0 | 10,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 6.600,0 | 6.600,0 | 6.597,0 | | 3,0 | | | | | | |
| ១៩. ក្រសួងបរិស្ថាន | 12.100,0 | 12.100,0 | 11.945,0 | | 140,0 | 15,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 8.100,0 | 8.100,0 | 7.945,0 | | 140,0 | 15,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 4.000,0 | 4.000,0 | 4.000,0 | | | | | | | | |
| ២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | 119.324,0 | 119.324,0 | 102.999,0 | | 16.315,0 | 10,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 8.050,0 | 8.050,0 | 5.400,0 | | 2.640,0 | 10,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 111.274,0 | 111.274,0 | 97.599,0 | | 13.675,0 | | | | | | |
| ២៣. ក្រសួងធម្មការ និង កិច្ចការសាសនា | 7.440,0 | 7.440,0 | 7.439,0 | | 1,0 | | | | | | |
| ១. រដ្ឋបាលកណ្តាល | 3.000,0 | 3.000,0 | 3.000,0 | | | | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 4.440,0 | 4.440,0 | 4.439,0 | | 1,0 | | | | | | |
| ២៤. ក្រសួងកិច្ចការនារី | 16.400,0 | 16.400,0 | 12.140,0 | | 4 242,0 | 18,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 9.000,0 | 9.000,0 | 5.985,0 | | 3.000,0 | 15,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 7.400,0 | 7.400,0 | 6.155,0 | | 1.242,0 | 3,0 | | | | | |
| ៣២. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | 29.093,0 | 29.093,0 | 24.268,0 | | 4.815,0 | 10,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 21.793,0 | 21.793,0 | 17.368,0 | | 4.415,0 | 10,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 7 300,0 | 7.300,0 | 6.900,0 | | 400,0 | | | | | | |
| ឃ. វិស័យសេដ្ឋកិច្ច | 252.374,0 | 252.374,0 | 227.715,0 | | 24.274,0 | 385,0 | | | | | |
| រដ្ឋបាលកណ្តាល | 173.783,0 | 173.783,0 | 158.554,0 | | 14.853,0 | 376,0 | | | | | |
| មន្ទីរជំនាញខេត្ត-ក្រុង | 78.591,0 | 78.591,0 | 69.161,0 | | 9.421,0 | 9,0 | | | | | |
| ០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 9.950,0 | 9.950,0 | 9.453,0 | | 472,0 | 25,0 | | | | | |
| ១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | 11.020,0 | 11 020,0 | 9.774,0 | | 1.231,0 | 15,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 5.100,0 | 5.100,0 | 4.789,0 | | 296,0 | 15,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 5.920,0 | 5.920,0 | 4.985,0 | | 935,0 | | | | | | |
| ១៥. ក្រសួងពាណិជ្ជកម្ម | 23.596,0 | 23.596,0 | 20.570,0 | | 3.019,0 | 7,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 19.846,0 | 19.846,0 | 16.820,0 | | 3.019,0 | 7,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 3.750,0 | 3.750,0 | 3.750,0 | | | | | | | | |
| ១៧. ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ | 59.474,0 | 59.474,0 | 45.256,0 | | 14.118,0 | 100,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 39.274,0 | 39.274,0 | 29.442,0 | | 9.732,0 | 100,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 20.200,0 | 20.200,0 | 15.814,0 | | 4.386,0 | | | | | | |
| ២០. ក្រសួងអភិវឌ្ឍន៍ជនបទ | 37.260,0 | 37.260,0 | 37.222,0 | | | 38,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 22.960,0 | 22.960,0 | 22.925,0 | | | 35,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 14.300,0 | 14.300,0 | 14.297,0 | | | 3,0 | | | | | |
| ២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | 32.520,0 | 32.520,0 | 31.705,0 | | 800,0 | 15,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 28.900,0 | 28.900,0 | 28.085,0 | | 800,0 | 15,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 3.620,0 | 3.620,0 | 3.620,0 | | | | | | | | |

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "ខ"

ទំព័រ៧/៣

## ចំណាយថវិកាជាតិរបស់រដ្ឋ

ឯកតា:លានរៀល

| ក្រសួង_ស្ថាប័ននានា | សរុបរួមចំណាយ | ចំណាយចរន្ត | | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុបចំណាយចរន្ត | ប្រភេទទី ១ មធ្យោបាយសេវា | ប្រភេទទី ២ បន្ទុកហិរញ្ញវត្ថុ | ប្រភេទទី ៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី ៤ ចំណាយផ្សេងៗ | ប្រភេទទី ៥ ចំណាយតាមដីកា | ប្រភេទទី ៦ ចំណាយមិនបានគ្រោងទុក | សរុបចំណាយមូលធន | ប្រភេទទី ១ ការទូទាត់ប្រាក់កម្ចី | ប្រភេទទី ២ អចលកម្ម |
| ២៥. ក្រសួងសាធារណការ និង ដឹកជញ្ជូន | 21 130,0 | 21.130,0 | 20.984,0 | | 40.0 | 106,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 9.500,0 | 9.500,0 | 9.360,0 | | 40.0 | 100,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 11.630,0 | 11.630,0 | 11.624,0 | | | 6,0 | | | | | |
| ២៧. ក្រសួងទេសចរណ៍ | 19.503,0 | 19.503,0 | 19.098,0 | | 400,0 | 5,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 15.143,0 | 15.143,0 | 14.738,0 | | 400,0 | 5,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 4.360,0 | 4.360,0 | 4.360,0 | | | | | | | | |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | 16.085,0 | 16.085,0 | 16.074,0 | | | 11,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 9.900,0 | 9.900,0 | 9.889,0 | | | 11,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 6.185,0 | 6.185,0 | 6.185,0 | | | | | | | | |
| ២៩. ក្រសួងធនធានទឹក និង ឧតុនិយម | 21.836,0 | 21.836,0 | 17.579,0 | | 4.194,0 | 63,0 | | | | | |
| ១. រដ្ឋបាលកណ្តាល | 13.210,0 | 13.210,0 | 13.053,0 | | 94,0 | 63,0 | | | | | |
| ៤. មន្ទីរជំនាញខេត្ត-ក្រុង | 8.626,0 | 8.626,0 | 4 526,0 | | 4.100,0 | | | | | | |
| ៤៤. ចំណាយមិនទាន់បែងចែក | 2.354.549,1 | 569.416,1 | | 50.000,0 | 137.500,0 | | | 381.916,1 | 1.785.133,0 | 100.000,0 | 1.685.133,0 |
| - បន្ទុកហិរញ្ញវត្ថុ ‹ ជំពូក ៦៦› | 50.000,0 | 50.000,0 | | 50.000,0 | | | | | | | |
| - ប្រាក់ឧបត្ថម្ភខេត្ត ក្រុង ‹ ជំពូក ៦៥› | 50.000,0 | 50.000,0 | | | 50.000,0 | | | | | | |
| - ប្រាក់ឧបត្ថម្ភឃុំ សង្កាត់ ‹ ជំពូក ៦៥› | 87.500,0 | 87.500,0 | | | 87.500,0 | | | | | | |
| - ចំណាយត្រៀមបម្រុង ‹ ជំពូក ០៩› | 349.916,1 | 349.916,1 | | | | | | 349.916,1 | | | |
| - ចំណាយផ្សេងៗ ‹ ជំពូក ០៩› | 32.000,0 | 32.000,0 | | | | | | 32.000,0 | | | |
| - ការទូទាត់ប្រាក់កម្ចី ‹ ជំពូក ១៦› | 100.000,0 | | | | | | | | 100.000,0 | 100.000,0 | |
| - គំរោងវិនិយោគ | 220.000,0 | | | | | | | | 220.000,0 | | 220.000,0 |
| - បដិភាគ | 125.000,0 | | | | | | | | 125.000,0 | | 125.000,0 |
| - វិនិយោគដោយមូលនិធិទ្រទ្រង់ថវិកា | 230.133,0 | | | | | | | | 230.133,0 | | 230.133,0 |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | 1.110.000,0 | | | | | | | | 1 110.000,0 | | 1.110.000,0 |

ទំព័រទី ១/១៤

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "គ១"

## ចំណាយមូលធនដែលផ្ទុះកិច្ចធនធានរបស់រដ្ឋ

## ផលនានានៃកម្មវិធី

ឯកតា:លានរៀលខ្មែរ

| លេខ គំរោង | ឈ្មោះគំរោង | តំលៃ គំរោង | ចាប់ផ្តើម ២០០៦ | កម្រិតទុនវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|---|
| | | | | ២០០៧ | ២០០៨ | ២០០៩ | សរុប ៣ ឆ្នាំ |
| ក្រសួងសុខាភិបាល | | | | | | | |
| 78 | ពង្រឹងសេវាសុខាភិបាលមូលដ្ឋាន | 508.821 | 13.000 | 30.000 | 35.000 | 40.000 | 105.000 |
| 79 | សុខភាពស្ត្រី និងកុមារ | 57.074 | 3.168 | 2.090 | 2.090 | 2.090 | 6.270 |
| 82 | កម្មវិធីប្រយុទ្ធនឹងជម្ងឺរបេង | 105.000 | 2.000 | 5.393 | 6.000 | 6.000 | 17.393 |
| 83 | ការប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់គ្រុនឈាម | 47.901 | 2.218 | 5.650 | 6.000 | 6.000 | 17.650 |
| 84 | កែទម្រង់ការចែកចាយឱសថស្ថាន និងសំភារៈបរិក្ខារពេទ្យ | 366 915 | 4.500 | 20.000 | 21 000 | 20.000 | 61.000 |
| 86 | កម្មវិធីជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងកាមរោគ | 58.811 | 4.662 | 8.181 | 9.859 | 10 000 | 28.040 |
| 87 | ការស្តារមន្ទីរពេទ្យជាតិ | 143 181 | 5.155 | 6.787 | 11.324 | 11 300 | 29.411 |
| 92 | ការថែរក្សាភ្នែក ច្រមុះ បំពង់ក | 8.155 | 500 | 500 | 500 | 500 | 1.500 |
| 426 | ត្រួតពិនិត្យគ្រប់គ្រងចំណីអាហារ និងថ្នាំសង្កូវ | 8.699 | 656 | 600 | 259 | 700 | 1.559 |
| 701 | អភិវឌ្ឍឱសថបូរាណ | 4.935 | 600 | 700 | 600 | 600 | 1.900 |
| 886 | លើកកម្ពស់សេវាត្រចៀក ច្រមុះ បំពង់ក ភ្នែក ធ្មេញ | 4 149 | 318 | 364 | 418 | 418 | 1.200 |
| 962 | គំរោងគ្រប់គ្រងជម្ងឺកុមារ (IMCI) | 5.567 | 500 | 500 | 500 | 500 | 1.500 |
| 1094 | ការត្រួតពិនិត្យគ្រុនផ្តាសាយនៅកម្ពុជា | 146 | 27 | - | - | | - |
| 1095 | គំរោងការពារជម្ងឺ HIV/AIDS | 476 | 119 | - | - | | - |
| 1096 | ការផ្តល់សុខភាពបឋមនៅខេត្តកំពង់ចាម | 5.213 | 1 303 | 1.303 | 1 086 | | 2.389 |
| 1097 | ការផ្តល់សេវាកម្មសុខភាពបឋមនៅខេត្តសៀមរាប និងឧត្តរមានជ័យ | 5.725 | 1 431 | 1.431 | 596 | | 2.028 |
| 1098 | មណ្ឌលសុខភាពនៃក្តីសង្ឃឹម (HOPE) សីហនុ | 1 414 | 283 | 283 | - | | 283 |
| 1099 | កម្មវិធីសុខភាពបន្តពូជ | 6.312 | 2.104 | - | - | | - |
| 1100 | គំរោងត្រួតពិនិត្យរបេង ជំហានទី២ | 592 | 118 | 118 | 118 | 118 | 355 |
| 1101 | គំរោងជួសជុលសាលាបច្ចេកទេសសុខាភិបាល | 377 | 40 | - | - | | - |
| 1102 | គំរោងអភិវឌ្ឍធនធានមនុស្សផ្នែកសុខាភិបាល | 1 291 | 254 | 254 | 191 | | 445 |
| 1103 | ការបង្កើតមន្ទីរពេទ្យទំនើបសម្រាប់កុមារកម្ពុជា | 1.206 | 603 | - | - | | - |
| 1104 | គាំទ្រវិស័យសុខាភិបាល | 28.051 | 6 011 | 5.510 | - | | 5.510 |
| 1105 | សហគមន៍សេវាកម្មសុខភាពបឋមនៅខេត្តបាត់ដំបង | 1 423 | 142 | 142 | - | | 142 |
| 1106 | សេវាកម្មសុខភាពបឋមសម្រាប់មាតា និងកុមារ នៅខេត្តកំពង់ស្ពឺ | 299 | 60 | 60 | - | | 60 |
| 1107 | ពង្រឹង និងពង្រីកកម្មវិធីការពារ | 62.390 | 4.500 | 6.500 | | | 6.500 |
| 1108 | កម្មវិធីវិមជ្ឈការ HIV / AIDS គ្រប់ខេត្តក្រុង | 1.926 | 600 | 750 | | | 750 |
| 1316 | អភិវឌ្ឍធនធាន និងសេវាសុខភាពផ្លូវចិត្ត | 5.466 | 691 | 486 | 486 | | 972 |
| 1317 | គោលនយោបាយមន្ទីរពេទ្យ និងធានាគាំពារសុខភាព | 780 | 188 | 592 | | | 592 |
| | សរុប | 1.442.294 | 55.751 | 98.195 | 96.027 | 98.226 | 292.448 |

សំគាល់: តំលៃចាប់ស្តាទពីក្រសួង-ស្ថាប័ននានា។ ប្រភពពត៌មាន:ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈក្រសួងផែនការ

# ការគ្រប់គ្រងឆ្នាំ ២០០៧

## តារាង "គ១"

## ចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ

## ឥណទាននៃកម្មវិធី

ឯកតា:ពាន់ដុល្លារអាមេរិក

| លេខគំរោង | ឈ្មោះគំរោង | តំលៃគំរោង | ប៉ាន់ស្មាន ២០០៦ | កម្រិតចុះវិនិយោគចែកតាមឆ្នាំ | | | |
|---|---|---|---|---|---|---|---|
| | | | | ២០០៧ | ២០០៨ | ២០០៩ | សរុប ៣ ឆ្នាំ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | | | | | | | |
| 719 | កម្មវិធីអភិវឌ្ឍសំភារៈរូបវ័ន្ត | 168.000 | 20.850 | 19.700 | 17 800 | 16.000 | 53.500 |
| 721 | ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សាទុតិយភូមិ | 10.341 | 1.200 | 1.425 | 1 750 | 1 750 | 4.925 |
| 722 | ការផ្គត់ផ្គង់សំភារៈសិក្សាគោល | 34.396 | 8.000 | 8.200 | 8.500 | 4.900 | 21.600 |
| 735 | ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅឧត្តមសិក្សា | 7.009 | 1.375 | 1.500 | 1.500 | 1 500 | 4.500 |
| 736 | លើកកម្ពស់ការឡើងថ្នាក់អប់រំបឋម | 65.762 | 8.600 | 8.600 | 10 600 | 11.000 | 30.400 |
| 797 | ការបំពេញការងារប្រកបដោយប្រសិទ្ធិភាពនៃសេវាអប់រំ | 26.113 | 1.000 | 2.200 | 3.400 | 7 000 | 12.600 |
| 876 | ការអប់រំមូលដ្ឋាននិងបណ្តុះបណ្តាលគ្រូបង្រៀននៅ ខេត្តសៀមរាប ឧត្តរមានជ័យ និងកំពង់ចាម | 14.106 | 3 527 | 2 697 | | | 2.697 |
| 998 | ពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ | 18.500 | 2.063 | 3.500 | 6.000 | 7 000 | 16.500 |
| 1070 | គំរោងសាងសង់សាលាបឋមសិក្សានៅភ្នំពេញ ជំហានទី២ | 4.600 | 800 | 3.000 | | | 3.000 |
| 1071 | កម្មវិធីពង្រីកការអប់រំមូលដ្ឋាន | 25.306 | 2.256 | 2.000 | 3 000 | 3 000 | 8.000 |
| 1072 | មជ្ឈមណ្ឌលអភិវឌ្ឍកម្មវិធី | 6.000 | 2.000 | 2.000 | | | 2.000 |
| 1073 | ថវិកាគាំទ្រកំណែទំរង់ការអប់រំមូលដ្ឋានដល់សិស្សក្រីក្រ | 24.704 | 2.296 | 4.000 | 9.000 | | 13.000 |
| 1074 | កម្មវិធីអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សា | 25.000 | 2.000 | 3.000 | 7 000 | 8.000 | 18.000 |
| 1075 | គំរោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សា | 33.000 | 2.000 | 3.000 | 7 000 | 7 000 | 17.000 |
| 1076 | គំរោងអភិវឌ្ឍវិស័យអប់រំ | 22.200 | 3.861 | 3.861 | - | | 3.861 |
| 1124 | សាលាសហគមន៍សម្រាប់ក្មេង | 950 | 56 | - | - | | - |
| 1125 | បណ្តុះបណ្តាលការទ្រទ្រង់ ចំណីអាហារ | 877 | 155 | - | - | | - |
| 1126 | ការអប់រំកើតមូលដ្ឋាននៅខេត្តកំពង់ចាម សៀមរាប និងឧត្តមានជ័យ | 10.938 | 2.734 | - | - | | - |
